**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
លេខ ២៩៣ ព.ណ កសបង.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញាតកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ/បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- យោងតាមការងារចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងការពារអ្នកប្រើប្រាស់ និងផលិតករ តាមរយៈការដាក់ឲ្យអនុវត្តនូវប្រព័ន្ធម៉ាកវិញ្ញាតកម្ម សំដៅជម្រាបដល់សាធារណជន ឬអ្នកប្រើប្រាស់ ថាមុខទំនិញ ឬសេវារបស់កម្មសិទ្ធិករ ដែលគាត់ប្រើប្រាស់ មានចរិតលក្ខណៈ ឬគុណភាពជាក់លាក់ ឬបានបំពេញនូវលក្ខណៈសម្បត្តិ ឬស្តង់ដារច្បាស់លាស់ ។

## ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់នីតិវិធីសម្រាប់ការចុះបញ្ជី កិច្ចការពារ និងការគ្រប់គ្រងម៉ាកវិញ្ញាតកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តលើសញ្ញាណាមួយ ដែលមានលក្ខណៈស្របតាមនិយមន័យនៃម៉ាកវិញ្ញាតកម្មដូចមានចែងក្នុងប្រការ ៤ និងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយអាចត្រូវបានចុះបញ្ជី និងការពារក្រោមប្រព័ន្ធម៉ាកវិញ្ញាតកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.- និយមន័យ

"ម៉ាកវិញ្ញាតកម្ម" សំដៅដល់ ឈ្មោះ និមិត្តសញ្ញា ឬរូបសញ្ញា ឬបង្គុំនៃសញ្ញាទាំងនោះដែលបង្ហាញថា ទំនិញនិង/ឬសេវានោះទាក់ទងនឹងម៉ាកវិញ្ញាតកម្មដែលបានប្រើប្រាស់ និងមានការបញ្ជាក់ពីម្ចាស់ម៉ាកបានចុះបញ្ជីរួចអំពី វត្ថុធាតុដើម ប្រភព វិធីសាស្ត្រ-របៀប ផលិតទំនិញឬផ្តល់សេវា គុណភាព ភាពច្បាស់លាស់ ឬចរិតលក្ខណៈផ្សេងទៀត។

## ប្រការ ៥.- បទប្បញ្ញត្តិដែលអនុវត្តបាន

លើកលែងតែមានចែងផ្ទុយពីប្រកាសនេះ បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធត្រូវយកមកអនុវត្តផងដែរចំពោះម៉ាកវិញ្ញាតកម្ម។

## ប្រការ ៦.- សមត្ថកិច្ចគ្រប់គ្រង

នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ចទទួលខុសត្រូវលើការចុះបញ្ជី កិច្ចការពារ និងការគ្រប់គ្រងម៉ាកវិញ្ញាតកម្ម តាមការផ្តល់សិទ្ធិដោយក្រសួងពាណិជ្ជកម្ម។

## ប្រការ ៧.- ភាពជាម្ចាស់ម៉ាកវិញ្ញាតកម្ម

១. អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវមានទ្រង់ទ្រាយជានីតិបុគ្គល និងមានសមត្ថភាពបញ្ជាក់លើទំនិញនិង/ឬសេវា សម្រាប់ម៉ាកវិញ្ញាតកម្មដែលត្រូវចុះបញ្ជី។

២. អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច មិនត្រូវប្រើប្រាស់ផ្ទាល់ខ្លួន ឬមានការពាក់ព័ន្ធនឹងការផលិត ការស្វែងរកទីផ្សារ ឬការធ្វើអាជីវកម្មផ្សេងទៀតលើទំនិញឬសេវាដែលដូច ឬប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវាសម្រាប់ម៉ាកវិញ្ញាតកម្មដែលត្រូវចុះបញ្ជី ។

៣. មិនត្រូវអនុញ្ញាតឲ្យ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច មកចុះបញ្ជីជាពាណិជ្ជសញ្ញា ឬសេវាសញ្ញាដែលដូច ឬប្រហាក់ប្រហែលចំពោះទំនិញឬសេវាដែលដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួចនោះឡើយ។

៤. មិនត្រូវអនុញ្ញាត ឲ្យអ្នកដាក់ពាក្យស្នើសុំ ឬម្ចាស់ពាណិជ្ជសញ្ញា ឬសេវាសញ្ញា ដែលបានដាក់ពាក្យ ឬចុះបញ្ជីរួចក្រោមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មកចុះបញ្ជីជាម៉ាកវិញ្ញាតកម្មដែលដូច ឬប្រហាក់ប្រហែលទៅនឹងពាណិជ្ជសញ្ញា ឬសេវាសញ្ញាចំពោះទំនិញឬសេវាដែលដូច ឬប្រហាក់ប្រហែលគ្នាឡើយ ។

៥. ការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ដែលបានចុះបញ្ជីរួចដោយភាគីណាមួយ ត្រូវមានការអនុញ្ញាតពីម្ចាស់ម៉ាកវិញ្ញាតកម្មនោះជាមុន។

**ប្រការ ៨.- ពាក្យស្នើសុំចុះបញ្ជី**

ពាក្យស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវធ្វើឡើងតាមគំរូពាក្យស្នើសុំជាភាសាខ្មែរ ឬអង់គ្លេស និងត្រូវដាក់ពាក្យដោយអនុលោមតាមមាត្រា ៥ ដល់ ៧ និងមាត្រា ៩ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវឯកសារតម្រូវដូចខាងក្រោម៖

១. លិខិតថ្លែងសច្ចារបស់អ្នកដាក់ពាក្យស្នើសុំ ថានឹងមិនពាក់ព័ន្ធក្នុងការផលិត ការស្វែងរកទីផ្សារ ឬផ្តល់សេវា ដែលមានលក្ខណៈដូច ឬប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវា ដែលម៉ាកវិញ្ញាតកម្ម នឹងត្រូវបានចុះបញ្ជី។

២. ភស្តុតាងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំនោះ មានទ្រង់ទ្រាយជានីតិបុគ្គល។

៣. បទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ត្រូវមានព័ត៌មានជាអប្បបរមាដូចខាងក្រោម៖

ក. ស្តង់ដារដែលទាក់ទងនឹង វត្ថុធាតុដើម ប្រភព វិធីសាស្ត្រនៃការផលិតទំនិញ ឬការផ្តល់សេវា គុណភាព ភាពច្បាស់លាស់ ឬចរិតលក្ខណៈផ្សេងទៀតដែលនឹងត្រូវបញ្ជាក់ដោយម៉ាកវិញ្ញាតកម្មនោះ

ខ. វិធីសាស្ត្រ-របៀបរបស់ម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច នឹងយកមកធ្វើ

ការផ្ទៀងផ្ទាត់ស្តង់ដារទាំងនោះ

គ. យន្តការរបស់ម្ចាស់ម៉ាកវិញ្ញាតកម្មដែលនឹងជួល ឲ្យធ្វើការគ្រប់គ្រងភាពត្រឹមត្រូវនៃការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និងភាពអនុលោមជាបន្តបន្ទាប់នៃស្តង់ដារខាងលើ

ឃ. វិធីសាស្ត្រ-របៀបនៃម៉ាកវិញ្ញាតកម្ម ដែលនឹងត្រូវបានប្រើប្រាស់លើទំនិញ និងសេវា

ច. កម្រៃសេវាដែលត្រូវបង់ជូនម្ចាស់ម៉ាកវិញ្ញាតកម្ម សម្រាប់ការប្រើប្រាស់ម៉ាកវិញ្ញាតកម្មនោះ ប្រសិនបើមាន

ឆ. នីតិវិធីដោះស្រាយវិវាទ។

៤. ឯកសារតម្រូវផ្សេងទៀត ដែលកំណត់ដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ឬបានបញ្ជាក់ក្នុងពាក្យស្នើសុំ។

៥. ម៉ាកវិញ្ញាតកម្មដែលដាក់ពាក្យស្នើសុំចុះបញ្ជីដោយនីតិបុគ្គលបរទេស ត្រូវភ្ជាប់មកជាមួយនូវភស្តុតាងនៃការចុះបញ្ជី ឬពាក្យស្នើសុំចុះបញ្ជីម៉ាកនោះក្នុងប្រទេសដើម ។

៦. លិខិតប្រគល់សិទ្ធិដែលមានបញ្ជាក់ភាពត្រឹមត្រូវ ប្រសិនបើពាក្យស្នើសុំនោះត្រូវបានដាក់តាមរយៈភ្នាក់ងារតំណាងម្ចាស់ម៉ាក ។

### ប្រការ ៩.- កម្រៃសេវាសាធារណៈ

កម្រៃសេវាសាធារណៈនៃម៉ាកវិញ្ញាតកម្ម ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ ។ នៅពេលកម្រៃសេវាសាធារណៈនៃម៉ាកវិញ្ញាតកម្មមិនទាន់បានកំណត់ ប្រកាសរួមរវាងក្រសួងទាំងពីរ ស្តីពីកម្រៃសេវាសាធារណៈក្នុងការចុះបញ្ជីម៉ាកដែលមានជាធរមានត្រូវបានយកមកអនុវត្ត ។

### ប្រការ ១០.- ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំ

១. នៅពេលដែលអ្នកដាក់ពាក្យស្នើសុំ ដាក់ពាក្យនិងបង់កម្រៃសេវាចុះបញ្ជីរួចរាល់ មន្ត្រីកាន់កាប់បញ្ជីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវត្រួតពិនិត្យមើលដូចខាងក្រោម៖

ក. ម៉ាកនោះមានលក្ខណៈសម្បត្តិដែលត្រូវការពារជាម៉ាកវិញ្ញាតកម្ម ស្របតាមប្រការ ៤ និងប្រការ ៧ នៃប្រកាសនេះ

ខ. ពាក្យស្នើសុំនោះ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ និង

គ. ម៉ាកវិញ្ញាតកម្មនោះ មិនអាចចុះបញ្ជីបានតាមមាត្រា ៤ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងមាត្រា១០ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

២. ក្នុងករណីដែលពាក្យសម្គាល់ប្រភពភូមិសាស្ត្រ ត្រូវបានប្រើប្រាស់ជាម៉ាកវិញ្ញាតកម្ម ឬជាផ្នែកមួយនៃម៉ាកវិញ្ញាតកម្ម ដើម្បីបញ្ជាក់ថាទំនិញនិង/ឬសេវានោះ ពិតជាមានប្រភពដើមក្នុងតំបន់ភូមិសាស្ត្រដែលបញ្ជាក់ដោយពាក្យនោះ មន្ត្រីកាន់កាប់បញ្ជីមិនត្រូវបដិសេធការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ផ្អែកតែលើមូលដ្ឋានថាជាម៉ាកមានលក្ខណៈពិពណ៌នាភូមិសាស្ត្រ ដោយយោងតាមមាត្រា៤(ក) នៃច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឡើយ ។ ប្រសិនបើពាក្យសម្គាល់ប្រភពភូមិសាស្ត្រនោះ មិនត្រូវបានប្រើប្រាស់ក្នុងគោលបំណងបញ្ជាក់ពីប្រភពដើមភូមិសាស្ត្រនៃទំនិញ ឬសេវានោះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធការចុះបញ្ជីម៉ាកនោះ ទោះបីពាក្យនោះត្រូវបានប្រើប្រាស់ជាម៉ាកវិញ្ញាតកម្ម ឬជាផ្នែកមួយនៃម៉ាកវិញ្ញាតកម្មនោះស្របតាមមាត្រា៤នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ក៏ដោយ។

៣. ក្នុងករណីដែលពាក្យស្នើសុំមិនបំពេញបានតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីអាចកែតម្រូវក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំចុះបញ្ជីដោយអ្នកដាក់ពាក្យតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកវិញ្ញាតកម្មនោះ។

៤. ក្នុងអំឡុងពេលធ្វើការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ មន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬបុគ្គលពាក់ព័ន្ធមកធ្វើការពន្យល់ ឬផ្តល់ភ័ស្តុតាងបន្ថែម ឬសុំយោបល់ពីអ្នកជំនាញក្នុងវិស័យ ឬផ្នែកពាក់ព័ន្ធដើម្បីសម្រេច ។

៥. ក្នុងករណីចាំបាច់ មន្ត្រីកាន់កាប់បញ្ជីអាចបង្កើតវិធានណែនាំបន្ថែមសម្រាប់ត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំចុះបញ្ជី និងការគ្រប់គ្រងម៉ាកវិញ្ញាតកម្ម ។

**ប្រការ ១១ .- ការចុះបញ្ជី និងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ**

១. ក្រសួងពាណិជ្ជកម្មត្រូវចុះបញ្ជីម៉ាកវិញ្ញាតកម្ម និងចេញវិញ្ញាបនបត្រជូនអ្នកដាក់ពាក្យស្នើសុំ ក្នុងករណីដែលពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌតម្រូវដូចបានកំណត់ក្នុងប្រការ ៥ និង ១០ នៃប្រកាសនេះ។

២. អនុលោមតាមមាត្រា ១០ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពផ្សាយម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច រួមជាមួយបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់នៃម៉ាកនោះក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម។

៣. រាល់ការកែតម្រូវ ការកែសម្រួល ការផ្ទេរកម្មសិទ្ធិ និងការផ្លាស់ប្តូរផ្សេងៗ ក៏ត្រូវធ្វើការបោះពុម្ពផ្សាយផងដែរ ។

**ប្រការ ១២.-សិទ្ធិទទួលបានពីការចុះបញ្ជី**

សិទ្ធិទទួលបានតាមរយៈការចុះបញ្ជីម៉ាកវិញ្ញាតកម្មមានដូចខាងក្រោម៖

១. កម្មសិទ្ធករនៃម៉ាកវិញ្ញាតកម្ម ត្រូវមានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឲ្យភាគីទីបីប្រើប្រាស់ម៉ាកវិញ្ញាតកម្មបានចុះបញ្ជីរួច ដើម្បីផលិត ឬស្វែងរកទីផ្សារទំនិញ ឬផ្តល់សេវាស្របតាមស្តង់ដារកំណត់ក្នុងបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម។ ការអនុញ្ញាតនេះ នឹងមិនត្រូវបានបដិសេធឡើយ ប្រសិនបើភាគីទីបីអាចបំពេញបាននូវរាល់លក្ខខណ្ឌតម្រូវទាំងឡាយដូចមានកំណត់ក្នុងបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់។

២. ប្រសិនបើអ្នកទទួលបានការអនុញ្ញាតក្នុងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម មិនបានបំពេញតាមស្តង់ដារតម្រូវទាំងអស់ដែលកំណត់ដោយបទប្បញ្ញត្តិនោះ ម្ចាស់ម៉ាកវិញ្ញាតកម្ម អាចដកហូតការអនុញ្ញាតរបស់ខ្លួនក្នុងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និង/ឬអាចចាត់វិធានការផ្សេងទៀត ដូចបានកំណត់ក្នុងបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់។

៣. ដើម្បីទប់ស្កាត់ ឬរារាំងការរំលោភបំពាន ម្ចាស់ម៉ាកវិញ្ញាតកម្ម អាចចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ ដើម្បីប្រឆាំងនឹងភាគីរំលោភបំពាន និងអាចស្វែងរកដំណោះស្រាយពាក់ព័ន្ធទាំងអស់ រួមទាំងសំណងចំពោះការខូចខាត វិធានការបណ្តោះអាសន្ន និងវិធានការតាមមាត់ច្រកព្រំដែន ដូចមានចែងក្នុងមាត្រា ២៤ ដល់មាត្រា ៤៧ និងមាត្រា ៦២ ដល់មាត្រា ៦៩ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

៤. ម្ចាស់ម៉ាកវិញ្ញាតកម្ម មានសិទ្ធិក្នុងការទប់ស្កាត់ការប្រើប្រាស់ម៉ាក ឬម៉ាកវិញ្ញាតកម្មដែលដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួចចំពោះទំនិញ និង/ឬសេវាដែលដូច ឬប្រហាក់ប្រហែលទៅនឹងទំនិញឬសេវាដែលម៉ាកវិញ្ញាតកម្មត្រូវចុះបញ្ជី ។

៥. សិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាកវិញ្ញាតកម្ម មិនមែនជាកម្មវត្ថុដើម្បីចាប់បង្ខំភាគីទីបីឲ្យទទួលនូវការធ្វើវិញ្ញាតកម្ម ដោយគ្មានការស្ម័គ្រចិត្តនោះឡើយ។

៦. សិទ្ធិដែលទទួលបានពីការចុះបញ្ជីម៉ាកវិញ្ញាតកម្ម មិនត្រូវបានផ្ទេរទាំងស្រុង ឬដោយផ្នែក លើកលែងតែនីតិបុគ្គលដែលនឹងទទួលបានសិទ្ធិពីម្ចាស់ម៉ាកវិញ្ញាតកម្មនោះ អនុវត្តតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ។ ការផ្ទេរសិទ្ធិនេះ ត្រូវមានការយល់ព្រមពីក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១៣.- ការចុះបញ្ជីម៉ាកវិញ្ញាតកម្មបរទេស**

១. ម៉ាកវិញ្ញាតកម្មបរទេស អាចត្រូវបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនម៉ាកនោះ បានបំពេញតាមលក្ខខណ្ឌតម្រូវទាំងឡាយដែលកំណត់ដោយប្រកាសនេះ និងបានចុះបញ្ជីស្របច្បាប់តាមបទប្បញ្ញត្តិនានាក្នុងប្រទេសដើមរួចហើយ។

២. មិនអនុញ្ញាតឲ្យចុះបញ្ជី ឬត្រូវបានលុបចេញពីបញ្ជី ក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះម៉ាកវិញ្ញាតកម្មបរទេស ដែលមិនត្រូវបានការពារ ឬបានបញ្ឈប់កិច្ចការពារ ឬបានឈប់ប្រើប្រាស់ក្នុងប្រទេសដើម ។

៣. ម៉ាកវិញ្ញាតកម្មបរទេស អាចដាក់ពាក្យស្នើសុំចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែធ្វើឡើងតាមរយៈភ្នាក់ងារតំណាង ដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៥៩ នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ១៤.- បណ្ដឹងជំទាស់**

អនុលោមតាមមាត្រា ១០ នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ភាគីពាក់ព័ន្ធអាចដាក់ពាក្យប្ដឹងជំទាស់នឹងការចុះបញ្ជីម៉ាកវិញ្ញាតកម្មមកក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជី ដោយឈរលើមូលដ្ឋាននៃលក្ខខណ្ឌតម្រូវមួយ ឬច្រើន ដូចមានចែងក្នុងប្រកាសនេះ ឬច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់មិនត្រូវបានបំពេញ។

**ប្រការ ១៥.- សុពលភាព**

១. បទប្បញ្ញត្តិស្ដីពី សុពលភាព និងការចុះបញ្ជីម៉ាកសាឡើងវិញ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវយកមកអនុវត្តផងដែរចំពោះម៉ាកវិញ្ញាតកម្ម។

២. ប្រសិនបើម៉ាកវិញ្ញាតកម្មឈប់ត្រូវបានការពារ ម៉ាកនោះមិនអាចយកមកស្នើសុំចុះបញ្ជីជាម៉ាកក្រោមច្បាប់ និងអនុក្រឹត្យស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឡើយ ។ ម៉ាកវិញ្ញាតកម្មបែបនេះមិនត្រូវបានប្រើប្រាស់ដោយបុគ្គលណាមួយ មុនរយៈពេលផុតសុពលភាព ១០ (ដប់) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់កិច្ចការពារនោះឡើយ លើកលែងតែក្រសួងពាណិជ្ជកម្មអនុញ្ញាតឲ្យមានការបន្តប្រព័ន្ធវិញ្ញាតកម្ម ដោយនីតិបុគ្គលផ្សេងដែលបង្ហាញភ័ស្តុតាងថាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃប្រការ ៨ នៃប្រកាសនេះ។

**ប្រការ ១៦.- ការត្រួតពិនិត្យអនុលោមភាព**

១. ម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច ត្រូវបង្កើតយន្តការផ្ទៀងផ្ទាត់ ដើម្បីធានាអនុលោមភាពទៅនឹងស្តង់ដារនៃការធ្វើវិញ្ញាតកម្ម ដូចមានចែងក្នុងប្រការ ៨(៣)(ខ) នៃប្រកាសនេះ ហើយត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំជូននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម រួមទាំងបញ្ជីផលិតផលនិងផលិតករដែលបានធ្វើវិញ្ញាតកម្ម តាមវិធានការនានាសម្រាប់ធ្វើវិញ្ញាតកម្ម ។ របាយការណ៍ និងឯកសារពាក់ព័ន្ធត្រូវធ្វើជាភាសាខ្មែរ ។ ក្នុងករណីដែលឯកសារធ្វើឡើងមិនមែនជាភាសាខ្មែរត្រូវភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសាខ្មែរ ដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ។

២. ក្នុងករណីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនបានផ្តល់របាយការណ៍ប្រចាំឆ្នាំ ឬក្នុងករណីដែលរកឃើញថា មិនមានអនុលោមភាពទៅនឹងស្តង់ដារនៃវិញ្ញាតកម្ម ក្រសួងពាណិជ្ជកម្មនឹងជូនដំណឹងទៅម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ដោយតម្រូវឲ្យដោះស្រាយការខកខានទាំងនោះក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីជូនដំណឹង។
តាមការស្នើសុំដោយមានហេតុផលច្បាស់លាស់ ពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ក្រសួងពាណិជ្ជកម្មអាចពន្យារពេលបន្ថែមទៀតមិនលើសពី ៩០(កៅសិប)ថ្ងៃ។ ប្រសិនបើនៅតែខកខានមិនបានបំពេញតាមការតម្រូវនេះ ម៉ាកវិញ្ញាតកម្មនោះនឹងត្រូវបានលុបចេញពីបញ្ជី។

**ប្រការ ១៧.- ការកែសម្រួល**

១. ក្រោយចុះបញ្ជីរួច និងក្នុងករណីមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ម្ចាស់ម៉ាកវិញ្ញាតកម្មអាចកែសម្រួលវិធីសាស្ត្រ និង/ឬនីតិវិធីសម្រាប់៖

ក. ធ្វើវិញ្ញាតកម្មអំពីចរិតលក្ខណៈ ស្តង់ដារ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញនិង/ឬសេវា

ខ. ធ្វើការត្រួតពិនិត្យការប្រើប្រាស់ម៉ាកវិញ្ញាតកម្មក្នុងវិស័យពាណិជ្ជកម្ម។

២. ក្រសួងពាណិជ្ជកម្ម នឹងឯកភាពលើការកែសម្រួល តាមការស្នើសុំពីម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច ប្រសិនបើការកែសម្រួលនោះមិនធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កម្មវត្ថុនិងស្តង់ដារដើមនៃម៉ាកវិញ្ញាតកម្មនោះ។

៣. ការកែសម្រួលខាងលើអាចធ្វើទៅបាន លុះត្រាតែការកែសម្រួលនោះមិនប៉ះពាល់ធ្ងន់ធ្ងរដល់កម្មវត្ថុ និងគម្រោងដើមនៃម៉ាកវិញ្ញាតកម្មនោះ ដែលពាក់ព័ន្ធទៅនឹងសមាសធាតុនៃការអភិវឌ្ឍបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ ។

**ប្រការ ១៨.- មោឃភាព និងការលុបចេញពីបញ្ជី**

១. ការធ្វើមោឃភាពនៃការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក. ម៉ាកវិញ្ញាតកម្ម មិនបានបំពេញលក្ខខណ្ឌតម្រូវណាមួយ ដូចមានចែងក្នុងប្រកាសនេះ និង

ខ. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនមានសិទ្ធិស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្មដូចមានចែងក្នុងប្រការ៤ និងប្រការ៧ នៃប្រកាសនេះ។

២. ការលុបម៉ាកវិញ្ញាតកម្មចេញពីបញ្ជី ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចលែងមានសមត្ថភាពធ្វើវិញ្ញាតកម្មលើទំនិញឬសេវា

ខ. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនអនុវត្តតាមកាលកំណត់ដូចមានចែងក្នុងប្រការ ១៥ នៃប្រកាសនេះ

គ. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច បានចាប់ផ្តើមប្រើប្រាស់ម៉ាកវិញ្ញាតកម្មផ្ទាល់ខ្លួនលើទំនិញ និង/ឬសេវា

ឃ. ការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ធ្វើឲ្យសាធារណជនភ័ន្តច្រឡំ

ង. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនបានប្រតិបត្តិតាមបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម

ច. ការកែសម្រួលណាមួយដែលបណ្តាលឲ្យបទប្បញ្ញត្តិខាងលើនេះ ផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌សង្គម និង

ឆ. ម៉ាកវិញ្ញាតកម្មបរទេស ដែលបានចុះបញ្ជីស្របតាមប្រការ ១៣ នៃប្រកាសនេះ លែងត្រូវបានការពារ ឬមិនត្រូវបានប្រើប្រាស់ក្នុងប្រទេសដើម។

៣. អនុភាពនៃការធ្វើមោឃភាព និងលុបការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវអនុវត្តទៅតាមមាត្រា ៣០ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

**ប្រការ ១៩.- បណ្តឹងតវ៉ា**

១. ជនណាដែលមានការពាក់ព័ន្ធ មានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាបណ្តឹងតវ៉ា ឬតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

២. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា ជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា។

**ប្រការ ២០.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន ស៊ូរស័ក្តិ**

<u>ចម្លងជូន៖</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។